## Saying "I don't know"





| | | |
|---|---|---|
| នៅកន្លែងធ្វើការ | វុទ្ធី ៖ | សោភា! ដឹងថាបងតារាទៅណាទេ ? |
| | សោភា ៖ | អត់ដឹងផង / អត់ដឹងដែរ / ខ្ញុំអត់ដឹងថាគាត់ទៅណាទេ វុទ្ធី ។ |
| | | កញ្ញា! ដឹងថាបងតារានៅណាទេ ? |
| | កញ្ញា ៖ | អម្បាញ់មិញឃើញគាត់នៅហ្នឹងទេតើ តែអត់ដឹងថាគាត់ទៅណាបាត់ហើយ ។ |
| នៅសាលារៀន | សុខា ៖ | ធារី! សួរមួយមើល ។ ចេះធ្វើលំហាត់នេះ / ស្រាយចំណោទនេះអត់ ? |
| | | ខ្ញុំគិតយូរហើយ នៅតែមិនចេញ ។ |
| | ធារី ៖ | ណា ? មើល ខ្ញុំមើលតិចមើល ។ ... អឹម ... ខ្ញុំគិតអត់ចេញដែរហ្នឹង ។ |
| | | អត់ដឹងថាត្រូវស្រាយយ៉ាងម៉េចទេនៀក ។ |
| នៅកន្លែងធ្វើការ | កញ្ញា ៖ | វុទ្ធី! កុំព្យូទ័រខ្ញុំខូចហើយ ។ វុទ្ធី ជួយមើលបន្តិចបានទេ ? |
| | វុទ្ធី ៖ | ខ្ញុំអត់សូវចេះកុំព្យូទ័រទេ កញ្ញា ។ ចាំខ្ញុំហៅបងតារាឲ្យមកជួយមើលណា ។ |
| នៅផ្ទះ | កូន ៖ | ម៉ាក់! ម៉ាក់ចេះធ្វើ ភីហ្សា អត់ ? ខ្ញុំចង់ញ៉ាំភីហ្សា ។ |
| | ម៉ាក់ ៖ | ម៉ាក់អត់ចេះទេកូន ។ ចាំម៉ាក់សួរគេមើល ក្រែងមានអ្នកចេះធ្វើ ។ |
| នៅកន្លែងធ្វើការ | វុទ្ធី ៖ | កញ្ញា! ល្ងាចហ្នឹងកញ្ញាទៅជប់លៀងអត់ ? |
| | កញ្ញា ៖ | ជប់លៀងអីគេ វុទ្ធី ? |
| | វុទ្ធី ៖ | ថ្ងៃនេះ ខួបកំណើតបងតារានោះអី! |
| | កញ្ញា ៖ | អូ អីចឹង ? ខ្ញុំអត់ដឹងសោះ! |

| | | | |
|---|---|---|---|
| វុទ្ធី តារា សុខា | male Cambodian names | ខ្ញុំមើលតិចមើល | Let me see ... |
| សោភា កញ្ញា សុខា ធារី | female Cambodian names | ខូច | to be broken |
| អត់ដឹងសោះ | I don't know at all | ភីហ្សា | pizza |
| ទៅណាបាត់ហើយ | he's left / he's gone | ក្រែង | maybe |
| សួរមួយមើល | Can I ask you a question? / Let me ask you a question. | ជប់លៀងអីគេ ? | What party? |
| លំហាត់ / ចំណោទ | exercise | ...នោះអី! | ..., isn't it? |
| ស្រាយ | to solve (an exercise) | អីចឹង ? | Really? |
| គិតមិន/អត់ចេញ | [I] can't figure it out | | |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

## Cultural notes

អត់ដឹងដែរ ជាពាក្យប្រើញឹកញាប់ជាងគេនៅពេលឆ្លើយថាយើងមិនដឹងអំពីអ្វីមួយ។ គេចូលចិត្តប្រើពាក្យ ដែរ នៅខាងចុង ព្រោះវាបង្កប់ន័យថាយើងក៏បានជួយគិតឬដោះស្រាយចម្ងល់របស់អ្នកសួរដែរ ប៉ុន្តែយើងនៅតែមិនដឹង។ ផ្ទុយទៅវិញ ពាក្យឆ្លើយថា អត់ដឹងទេ ស្តាប់ទៅមិនសូវពីរោះប៉ុន្មានទេ ព្រោះវាហាក់ដូចជាបង្កប់ន័យថាយើងមិនខ្វល់អំពីបញ្ហារបស់អ្នកសួរ។

| | |
|---|---|
| បង្កប់ន័យ | to imply |
| ដោះស្រាយ | to solve, to attend to (a problem), to explain |
| ចម្ងល់ | doubt |
| ផ្ទុយទៅវិញ | on the contrary |
| ស្តាប់ទៅ | it sounds |
| ពីរោះ | (sounds) good, beautiful, here: polite, friendly |
| វាហាក់ដូចជា | it seems to, it is like |
| មិនសូវ ... ប៉ុន្មានទេ | not very, not much, not so |
| មិនខ្វល់អំពី | to not care about |

## Additional dialogue

| | | |
|---|---|---|
| នៅកន្លែងធ្វើការ | តារា៖ | មានអ្នកណាគេឃើញសៀវភៅមួយក្បាលលើតុនេះមិញអត់? |
| | កញ្ញា៖ | ខ្ញុំអត់ដឹងផងបង។ |
| | វុទ្ធី៖ | វចនានុក្រមមែនបង? ខ្ញុំយកទៅទុកលើធ្នើរបាត់ហើយ។ |
| | តារា៖ | ហ្នឹងហើយ វចនានុក្រម។ បងយកវាចុះមកមើលហ្នឹងណា តែរវល់ពេក អត់ទាន់បានមើលផង។ |
| | វុទ្ធី៖ | អូ សុំទោសបង។ ខ្ញុំអត់ដឹងថាបងទុកមើល។ ស្មានតែអ្នកណាគេភ្លេចទុកវិញ។ ចាំខ្ញុំយកឲ្យវិញបង។ |

| | |
|---|---|
| មិញ = អម្បាញ់មិញ | just now |
| វចនានុក្រម | dictionary |
| ធ្នើរ | shelf |
| ខ្ញុំយកទៅទុកលើធ្នើរ | I've put it back on the shelf |
| ស្មានតែ... | I thought ... |
| ភ្លេចទុកវិញ | forgot to put it away |
| ខ្ញុំយកឲ្យវិញ | I'll bring it back |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.